# សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភា

## កម្ពុជា បារាំង អង់គ្លេស អាម៉េរិក កាណាដា និងអូស្ត្រាលី





ខែមីនា ឆ្នាំ២០២៦

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំសូមជម្រាបជូនថា គំនិតដើមនៃការសិក្សានេះ កើតឡើង ដោយសារទស្សនទានរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការពង្រឹងការទូតសភា និងគណនេយ្យភាពសភាជាមួយអង្គបោះឆ្នោត និងប្រជាជននៅតាមមូលដ្ឋានសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥។

ដើម្បីពង្រឹងគណនេយ្យភាពសភា ពោលគឺបង្កើនការទទួលខុសត្រូវ និងបង្ខិតសមាជិកព្រឹទ្ធសភា ឱ្យកាន់តែជិតជាមួយអង្គបោះឆ្នោត និងប្រជាជននៅតាមមូលដ្ឋាន គណៈកម្មការពិសេស ត្រូវបានបង្កើតឡើង ដើម្បីសិក្សាស្រាវជ្រាវអំពី ប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជាប្រៀបធៀបជាមួយប្រព័ន្ធបោះឆ្នោតសភាជាន់ខ្ពស់ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ ឥណ្ឌូណេស៊ី បារាំង អង់គ្លេស អាម៉េរិក កាណាដា និងអូស្ត្រាលី។

គណៈកម្មការពិសេស បានបំពេញភារកិច្ចរបស់ខ្លួន ដោយបានសិក្សាស្រាវជ្រាវ ពិភាក្សា រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងរៀបចំជាអត្ថបទស្រាវជ្រាវ រហូតទទួលបានលទ្ធផលជាទីគាប់ចិត្ត ពោលគឺការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវចំនួនពីរដូចខាងក្រោម៖

១. សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី និង

២. សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជា បារាំង អង់គ្លេស អាម៉េរិក កាណាដា និងអូស្ត្រាលី។

តាងនាមគណៈកម្មការពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** ដែលតែងតែផ្តល់យោបល់ណែនាំ និងលើកទឹកចិត្តដល់ការស្រាវជ្រាវរបស់គណៈកម្មការពិសេស។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សមាជិក និងលេខាធិការគណៈកម្មការពិសេសរួមមាន លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី, ឯកឧត្តមបណ្ឌិត ប៉ែម រីឡ៉ា, ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី, ឯកឧត្តមបណ្ឌិត នាង ផាត, ឯកឧត្តម អ៊ុំ សារឹទ្ធ, ឯកឧត្តម ងី ច័ន្ទ្រផល, ឯកឧត្តម ឡាយ សំកុល, ឯកឧត្តមបណ្ឌិត ភឹម រុនស៊ីណារិទ្ធិ, ឯកឧត្តម ប៊ុន វុទ្ធា, លោកជំទាវ សួន ពុធថាវី, លោកជំទាវ សុខ លក្ខិណា, លោក រស់ សុភារុធ និង លោក ឃិន យូរ៉ាន់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងដំណើរការសិក្សាស្រាវជ្រាវនេះ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ គណៈកម្មការពិនិត្យអត្ថបទសិក្សានៃសាកលវិទ្យាល័យជាតិគ្រប់គ្រងរួមមាន ឯកឧត្តមសាស្ត្រាចារ្យ ហោ ប៉េង សាស្ត្រាចារ្យរង គង់ ផល្លៈ, សាស្ត្រាចារ្យរង ណុប កញ្ញារិទ្ធិ, សាស្ត្រាចារ្យជំនួយ គឹម វារ៉ា, និងសាស្ត្រាចារ្យជំនួយ ប៉ុក ភារុន ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់ធាតុចូលផ្នែកបច្ចេកទេស ដើម្បីឱ្យអត្ថបទនេះកាន់តែសុក្រឹត។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តមបណ្ឌិត សន ពៅ ដែលបានជួយពិនិត្យឃ្លា ល្បះ និងអក្ខរាវិរុទ្ធលើអត្ថបទស្រាវជ្រាវនេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា តំណាងគណបក្សនយោបាយសម្ព័ន្ធភាព តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងយុត្តិធម៌ តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតំណាងក្រុមប្រឹក្សាសាកលវិទ្យាធិការនៃ

កម្ពុជា ដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងបានផ្តល់ធាតុចូលសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦



**បណ្ឌិត ធន់ វឌ្ឍនា**

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ i
សង្ខេបខ្លី ........ 1
១. សេចក្តីផ្តើម ........ 3
២. វិធីសាស្ត្រស្រាវជ្រាវ ........ 5
៣. លទ្ធផល ........ 6
៣.១. កម្រិតដែនដីរដ្ឋបាល ........ 6
៣.២.ប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ប្រទេសមួយចំនួន ........ 9
៣.២.១. សភាជាន់ខ្ពស់កម្ពុជា ........ 10
៣.២.២. សភាជាន់ខ្ពស់បារាំង ........ 12
៣.២.៣. សភាជាន់ខ្ពស់ចក្រភពអង់គ្លេស ........ 14
៣.២.៤. សភាជាន់ខ្ពស់សហរដ្ឋអាម៉េរិក ........ 17
៣.២.៥. សភាជាន់ខ្ពស់កាណាដា ........ 18
៣.២.៦. សភាជាន់ខ្ពស់អូស្ត្រាលី ........ 21
៣.៣. ការវិភាគប្រៀបធៀប ........ 23
៣.៣.១. ភាពតំណាង និងគណនេយ្យភាព ........ 24
៣.៣.២. ប្រសិទ្ធភាពគណនេយ្យភាពសភា ........ 27
៤.សន្និដ្ឋាន ........ 30
៥. អនុសាសន៍ ........ 31
ឯកសារយោង ........ 33

# សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភា កម្ពុជា បារាំង អង់គ្លេស សហរដ្ឋអាម៉េរិក កាណាដា និងអូស្ត្រាលី[1]

## សង្ខេបខ្លី


អត្ថបទនេះ វិភាគប្រៀបធៀបប្រព័ន្ធបោះឆ្នោត ជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ (ព្រឹទ្ធសភា) នៅកម្ពុជា បារាំង អង់គ្លេស សហរដ្ឋអាម៉េរិក កាណាដា និងអូស្ត្រាលី ដោយផ្ដោតលើមណ្ឌលបោះឆ្នោត ចំនួនអាសនៈ អាណត្តិ និងវិធីសាស្ត្របោះឆ្នោត ដើម្បីស្វែងរកឧត្តមានុវត្តជាអនុសាសន៍ដល់កម្ពុជា ឆ្ពោះទៅពង្រឹងភាពតំណាង និងគណនេយ្យភាពសភាឱ្យកាន់តែមានប្រសិទ្ធភាព។


ជាទូទៅ ការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ ធ្វើនៅមណ្ឌលបោះឆ្នោតកម្រិតជាតិ ឬដែនដីរដ្ឋបាលកម្រិត១ (រាជធានី-ខេត្ត ឬ រដ្ឋករណីប្រទេសមានរដ្ឋាភិបាលសហព័ន្ធ) ឬដែនដីរដ្ឋបាលកម្រិត២ (ក្រុង/ស្រុក/ខណ្ឌ) អាស្រ័យតាមប្រទេសនីមួយៗ។ សមាជិកព្រឹទ្ធសភាបារាំងទាំង ៣៤៨រូប ត្រូវឆ្លងកាត់ការបោះឆ្នោតអសកល២ជុំ ទៅតាមមណ្ឌលបោះឆ្នោតនៅដែនដីរដ្ឋបាលកម្រិត២ (Département[2] = ក្រុង/ស្រុក/ខណ្ឌ) ដែលមានចំនួន ១០១ Département។ សមាជិកព្រឹទ្ធសភាបារាំង មានអាណត្តិ៦ឆ្នាំ និងបោះឆ្នោតពាក់កណ្ដាលរៀងរាល់ ៣ឆ្នាំម្ដង។ រីឯនៅអង់គ្លេស សមាជិកព្រឹទ្ធសភា មិនឆ្លងកាត់ការបោះឆ្នោតនោះទេ និងមានសមាជិកច្រើនចំនួនដល់ ៨៥០រូប

[1] អត្ថបទនេះសរសេរដោយក្រុមស្រាវជ្រាវ៖ ធន់ វឌ្ឍនា ហោ ប៉េង សុខ លក្ខិណា និង ភឹម រុនសុីណារិទ្ធិ។

[2] យោងមាត្រា ៧២ នៃរដ្ឋធម្មនុញ្ញបារាំង (១៩៥៨) រដ្ឋបាលថ្នាក់ក្រោមជាតិរបស់បារាំងត្រូវបានបែងចែកជាច្រើនថ្នាក់ពោលគឺ Region ដែលធំជាង Department និង Commune។

ដែលត្រូវបានជ្រើសតាំងក្នុងចំណោមអភិជន បព្វជិត និងឥស្សរជនឆ្នើមៗ នៅក្នុងសង្គម មានដូចជា អភិជនតវង្សត្រកូល អភិជនឆ្នើម សម្ដេចសង្ឃរាជ (Archbishops) និងបុគ្គលឆ្នើមក្នុងអាជីពដែលទទួលបានការគោរពពីសង្គម មានអាណត្តិមួយជីវិត (UK Parliament, 2025)។

សមាជិកព្រឹទ្ធសភាសហរដ្ឋអាម៉េរិក និងអូស្ត្រាលី កើតចេញពីការបោះឆ្នោតសកល ដែលមានមណ្ឌលបោះឆ្នោត នៅដែនដីរដ្ឋបាលកម្រិត១។ មណ្ឌលបោះឆ្នោតសមាជិកព្រឹទ្ធសភា សហរដ្ឋអាម៉េរិក គឺរដ្ឋទាំង ៥០ ដោយកំណត់ចំនួនសមាជិក ២រូបក្នុង១រដ្ឋ (មិនគិតរដ្ឋតូច ឬធំនោះឡើយ) សរុប ១០០រូប សម្រាប់អាណត្តិ៦ឆ្នាំ និង១/៣នៃសមាជិកព្រឹទ្ធសភាទាំងអស់ នឹងត្រូវបានបោះឆ្នោតជ្រើសតាំង២ឆ្នាំម្ដង (U.S. Senate, 2025)។ ចំណែកឯអូស្ត្រាលី មណ្ឌលបោះឆ្នោត គឺរដ្ឋចទាំង៦ និងដែនដី២ ដោយកំណត់ចំនួនសមាជិកព្រឹទ្ធសភា ១២ រូប ក្នុង១រដ្ឋ និង ២រូប ក្នុង១ដែនដី សរុប ៧៦រូប សម្រាប់អាណត្តិ៦ឆ្នាំ (វៀរលែងសមាជិកព្រឹទ្ធសភាមកពីមណ្ឌលដែនដី ដែលមានអាណត្តិ៣ឆ្នាំ) និងរៀបចំការបោះរៀងរាល់៣ឆ្នាំម្ដង (Parliament of Australia, 2025) ។

សមាជិកព្រឹទ្ធសភាកាណាដា កើតចេញពីការជ្រើសតាំងទាំងស្រុង ដូចនឹងព្រឹទ្ធសភាអង់គ្លេសដែរ ប៉ុន្តែជ្រើសសមាជិកទៅតាមតំបន់ចំនួន៥ ដែនដីចំនួន៣ និងកំណត់ចំនួនអាសនៈតាមរដ្ឋធម្មនុញ្ញ ដែលអាសនៈសរុប១០៥។ បេក្ខជនមានអាយុ យ៉ាងតិច៣០ឆ្នាំជាបុគ្គលឆ្នើមៗក្នុងអាជីពដែលទទួលបានការគោរពពីសង្គម អាចដាក់ពាក្យសុំធ្វើជាសមាជិកព្រឹទ្ធសភាតំណាងឱ្យតំបន់ខ្លួនបានប្រសិនត្រូវបានជ្រើសតាំង

ជាសមាជិកព្រឹទ្ធសភា នោះនឹងត្រូវបំពេញការងារជាសមាជិកព្រឹទ្ធសភា រហូតដល់ចូលនិវត្ត នៅអាយុ៧៥ឆ្នាំ( Parliament of Canada, n.d. )។

លទ្ធផលស្រាវជ្រាវបង្ហាញថា ប្រព័ន្ធបោះឆ្នោតអសកលរបស់បារាំង ធ្វើឱ្យមានតំណាងក្នុងដែនដីរដ្ឋបាលកម្រិត២ រីឯការបោះឆ្នោតសកលរបស់សហរដ្ឋអាម៉េរិក និងអូស្រ្តាលី ផ្តោតលើគណនេយ្យភាពចំពោះអ្នកបោះឆ្នោត ឯប្រព័ន្ធតែងតាំងចក្រភពអង់គ្លេស និងកាណាដាផ្តល់អាទិភាពលើវិជ្ជាជីវៈ ប៉ុន្តែប្រឈមមុខនឹងបញ្ហាប្រជាធិបតេយ្យ។ ប្រព័ន្ធជ្រើសតាំងសមាជិកព្រឹទ្ធសភានៃបណ្តាប្រទេសទាំងនេះមានចំណុចល្អ និងបញ្ហាប្រឈមខុសៗគ្នា ដែលកម្ពុជា អាចទាញយកបទពិសោធធ្វើឱ្យប្រសើរឡើងនៃភាពតំណាងសភា និងគណនេយ្យភាពសភាកម្ពុជាបាន។ ក្នុងចំណោមប្រទេសស្ថិតក្រោមការសិក្សានេះ ការបោះឆ្នោតព្រឹទ្ធសភាធ្វើឡើងនៅដែនដីកម្រិត១ ឬកម្រិត២ ប៉ុន្តែកម្ពុជា ធ្វើឡើងនៅកម្រិតភូមិភាគ គឺយកខេត្តបូកបញ្ចូលគ្នា (ចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១) ។ ការសិក្សានេះស្នើថា ដើម្បីពង្រឹងភាពតំណាង និងគណនេយ្យភាពព្រឹទ្ធសភាកម្ពុជា មណ្ឌលបោះឆ្នោត គួរកែសម្រួលពីកម្រិតភូមិភាគ ទៅដែនដីរដ្ឋបាលកម្រិត១ និងកំណត់ចំនួនអាសនៈសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលបោះឆ្នោតនីមួយៗ ផ្អែកទៅតាមទំហំមណ្ឌលបោះឆ្នោត។

## ១. សេចក្តីផ្តើម

ប្រព័ន្ធសភានិយម ដែលជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យសម័យទំនើប មានប្រភពដើមពីប្រព័ន្ធនយោបាយរបស់ចក្រភពអង់គ្លេស (Research Starters, 2025)។ កាលដើមឡើយ ប្រព័ន្ធសភាកើតចេញ

ពីការប្រមូលផ្តុំអ្នកតំណាងនានា (សភាពិគ្រោះយោបល់) ដែលបានចូលរួមក្នុងការពិភាក្សាមួយ លើប្រធានបទមួយ ឬបញ្ហាមួយ។ លុះក្រោយមកពាក្យ "សភា" (Parliament) ត្រូវបានប្រើប្រាស់ជាលើកដំបូងនៅក្នុងឆ្នាំ ១២៣៦ ដោយស្តេច Henry III នៃចក្រភពអង់គ្លេស។ យូរៗទៅ ការប្រមូលផ្តុំអ្នកតំណាង ឬក៏សភានេះ បានវិវត្តពីវេទិកាជជែកអំពីការយកពន្ធ ទៅជាស្ថាប័នដែលមានអំណាចនីតិប្បញ្ញត្តិ និងអំណាចរដ្ឋបាលដ៏ខ្លាំងមួយ។ ប្រព័ន្ធសភាទំនើបបានលេចចេញជារូបរាងបន្ទាប់ពីព្រឹត្តិការណ៍នៃបដិវត្តន៍ (Glorious Revolution) ក្នុងចន្លោះឆ្នាំ១៦៨៨-១៦៨៩។ ពេលនោះមានការកំណត់មុខងារប្រតិបត្តិ ដែលទទួលបន្ទុកដោយសមាជិកភាព និងកំណត់ឱ្យនាយករដ្ឋមន្ត្រី ត្រូវទទួលខុសត្រូវ ចំពោះមុខស្ថាប័ននីតិប្បញ្ញត្តិ (Research Starters, 2025; Britannica, 2024)។

លក្ខណៈសំខាន់មួយនៅក្នុងប្រព័ន្ធសភានិយម គឺការរៀបចំជាប្រព័ន្ធទ្វេសភា (bicameralism) ដែលសភាត្រូវបានបែងចែកជាសភាជាន់ទាប និងសភាជាន់ខ្ពស់ (Wikipedia, 2023; Investopedia, 2024)។ ប្រព័ន្ធទ្វេសភាបែបទំនើប ក៏មានប្រភពដើមចេញពីប្រព័ន្ធសភានិយមនៅចក្រភពអង់គ្លេសនាសតវត្សរ៍ទី១៧។ នៅអង់គ្លេស សភាត្រូវបានបែងចែកជាពីរថ្នាក់ ស្របតាមប្រព័ន្ធវណ្ណៈសង្គមនាសម័យនោះ គឺសភាតំណាងរាស្ត្រ (House of Common) និងសភាអភិជន (House of Lord) ដើម្បីតំណាងឱ្យថ្នាក់សង្គមផ្សេងគ្នា។ សព្វថ្ងៃនេះ ប្រហែល ៤០% នៃសភាលើពិភពលោក គឺមានពីរថ្នាក់ ដែលជារឿយៗត្រូវបានរកឃើញនៅក្នុងរដ្ឋសហព័ន្ធ រដ្ឋធំៗ និងរដ្ឋដែលអនុវត្តរបបប្រធានាធិបតី។

ប្រព័ន្ធទ្វេសភាមានសារៈសំខាន់ ដោយសារការបែងចែកអំណាចនីតិប្បញ្ញត្តិរវាងសភាទាំងពីរ ជួយរារាំងការប្រើប្រាស់អំណាចផ្តាច់មុខរបស់ក្រុមតែមួយ ពីការត្រួតត្រាលើការបង្កើតច្បាប់ ការត្រួតពិនិត្យ និងការធ្វើឱ្យមានតុល្យភាពនៃអំណាច។ ប្រព័ន្ធនេះ ជួយពង្រឹងឱ្យមានការគិតគូរពិចារណា និងត្រួតពិនិត្យច្បាប់បានហ្មត់ចត់ មុនពេលបង្កើតច្បាប់ ឬធ្វើវិសោធនកម្មច្បាប់ ដែលកាត់បន្ថយកំហុសនៃការសម្រេចចិត្តលឿន។ ប្រព័ន្ធទ្វេសភា ធ្វើឱ្យមានភាពជាតំណាង ផ្សេងៗគ្នាក្នុងតំបន់ និងផលប្រយោជន៍ផ្សេងៗគ្នាទៅតាមក្រុមប្រជាជនផ្សេងៗ ដែលរួមចំណែកដល់ការរក្សាស្ថិរភាពនយោបាយ។

សភាជាន់ខ្ពស់ (ព្រឹទ្ធសភា) នៅក្នុងប្រព័ន្ធអភិបាលកិច្ចបែបប្រជាធិបតេយ្យ គឺការរក្សាតុល្យភាពនៃមុខងារតំណាង មុខងារនីតិកម្ម និងស្ថិរភាពនយោបាយ ដែលបត់បែនទៅតាមបរិបទ រដ្ឋធម្មនុញ្ញ និងប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភាទៅតាមប្រព័ន្ធជ្រើសតាំង ឬតែងតាំងក្នុងប្រទេសនីមួយៗ ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន គឺបានវិវត្តទៅតាមការផ្លាស់ប្តូរនៃបរិបទសង្គមនយោបាយ និងប្រវត្តិសាស្ត្ររបស់ប្រទេសទាំងនោះ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយ គណៈកម្មការពិសេស ដែលមានសមាសភាព១៤រូប និងត្រូវបានបែងចែកជា ៣ក្រុម។ ក្រុមទី១ សិក្សាលើករណីកម្ពុជា ក្រុមទី២ សិក្សាលើករណីប្រទេសបារាំង អូស្ត្រាលី អាម៉េរិក កាណាដា និងចក្រភពអង់គ្លេស រីឯក្រុមទី៣ សិក្សាលើករណីប្រទេសជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី។ ការ

សិក្សាស្រាវជ្រាវនេះ គឺផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ក្រុមទី១ និងក្រុមទី២។

អ្នកស្រាវជ្រាវក្នុងក្រុមទី១ និងក្រុមទី២ បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យនិងព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយរួចជាស្រេច (Secondary Data) ចេញពីប្រភពផ្សេងៗ រួមមានច្បាប់រដ្ឋធម្មនុញ្ញ ទិនានុប្បវត្តិសិក្សា អត្ថបទស្រាវជ្រាវ សៀវភៅ របាយការណ៍ ឯកសារគោលនយោបាយ ទស្សនាវដ្ដី កាសែត និងគេហទំព័រផ្លូវការមួយចំនួនរបស់ស្ថាប័នពាក់ព័ន្ធ។ បន្ទាប់មក មានការវិភាគ និងសំយោគឯកសារសម្រាប់កិច្ចប្រជុំពិភាក្សាចំនួន៧លើក ហើយមានការកែលម្អភាពចំណុចមួយចំនួន ដើម្បីធានាសុក្រឹតភាព និងសុគតភាព របស់អត្ថបទនេះ។

សិក្ខាសាលាប្រឹក្សាយោបល់មួយត្រូវបានរៀបចំកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ដើម្បីប្រមូលធាតុចូលបន្ថែម ពីភាគីពាក់ព័ន្ធរួមមានសមាជិកព្រឹទ្ធសភា តំណាងគណៈកម្មការទាំង១០នៃរដ្ឋសភា តំណាងគណបក្សនយោបាយ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងយុត្តិធម៌ តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតំណាងក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា។

## ៣. លទ្ធផល

### ៣.១. កម្រិតដែនដីរដ្ឋបាល

ជាទូទៅ ដែនដីរដ្ឋបាលត្រូវបានបែងចែកពី ២-៤ កម្រិត ដែលប្រទេសភាគច្រើន កំណត់ឱ្យមានដែនដីរដ្ឋបាល ៣កម្រិត (Fontanelli

et al., 2017)។ ការបែងចែកកម្រិតផ្សេងៗគ្នានេះ គឺអាចបណ្ដាលមកពីឥទ្ធិពលនៃកត្តាវប្បធម៌ ប្រវត្តិសាស្ត្របន្តគ្នារបស់ប្រទេសនីមួយៗ កត្តាសង្គមសេដ្ឋកិច្ច នយោបាយ ឬឥទ្ធិពលនៃអាណាព្យាបាលឬអាណានិគមរបស់ប្រទេសមហាអំណាចធំៗ ដែលបានដាក់មកលើប្រទេសតូចៗ។ អត្ថបទស្រាវជ្រាវនេះ បរិយាយពីដែនដីរដ្ឋបាលត្រឹម៣កម្រិត របស់ប្រទេសកម្ពុជា បារាំង សហរដ្ឋអាម៉េរិក កាណាដា អង់គ្លេស និងអូស្ត្រាលី ដូចមានបង្ហាញក្នុងតារាង១។

កម្រិតដែនដីរដ្ឋបាលទាំង៣កម្រិតនេះ មានឈ្មោះហៅខុសៗគ្នាក្នុងកម្រិតនីមួយៗ។ ឧទាហរណ៍ ដែនដីរដ្ឋបាលកម្រិត១ ត្រូវបានហៅថា រាជធានី/ខេត្ត (Province) សម្រាប់ប្រទេសកម្ពុជា ដែលដូចទៅនឹងប្រទេសកាណាដា ប៉ុន្តែដែនដីរដ្ឋបាលកម្រិត១នេះខុសពីសហរដ្ឋអាម៉េរិក និងអូស្ត្រាលីដែលត្រូវបានហៅថា រដ្ឋ (State) ដែនដីរដ្ឋបាលកម្រិត១នៅអង់គ្លេសត្រូវបានហៅថា County[3] និងដែនដីរដ្ឋបាលកម្រិត១នៅបារាំងត្រូវបានហៅថា Region/Overseas Collectivity។ ឈ្មោះដែនដីរដ្ឋបាលកម្រិត២ និងកម្រិត៣ ក៏ខុសគ្នាដែរចំណោមប្រទេសទាំង៦។

[3] ក្នុងចក្រភពអង់គ្លេស (United Kingdoms) មាន អង់គ្លេស (England) ស្កុតឡេន (Scotland) វែល (Wales) និងអៀរឡង់ខាងជើង (Northern Ireland) ដែលពួកគេត្រូវបានគេហៅថាជា "ប្រទេស -Country" ផងដែរ។ ដូច្នេះ គេអាចនិយាយថា ចក្រភពអង់គ្លេសជាប្រទេស ដែលមានប្រទេសនៅក្នុងប្រទេស ។

## តារាង១: ដែនដីរដ្ឋបាល ៣កម្រិត

| ប្រទេស | កម្រិត១ | កម្រិត២ | កម្រិត៣ |
|---|---|---|---|
| កម្ពុជា | រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ |
| បារាំង | Region/Oversea Collectivity | Department | Arrondissements/Quarter/ Communes/District |
| អាមេរិក | State | County | Township/Municipality |
| អង់គ្លេស | London/County | Borough/District | Ward/Parish |
| កាណាដា | Province/ Territory | Municipality/County/District | Hamlet/Municipality/Parish |
| អូស្ត្រាលី | State/ Territory | Council/Shire/City/Town | Ward |

**ប្រភព:** https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country

ចំពោះដែនដីរដ្ឋបាល ដែលត្រូវបានប្រើប្រាស់សម្រាប់ជាមណ្ឌលបោះឆ្នោត និងការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ប្រទេសទាំង៦នេះក៏ខុសគ្នាដែរ។ ប្រទេសអង់គ្លេស និងកាណាដា មានជ្រើសតាំងសមាជិកកម្រិតជាតិ ខណៈអូស្ត្រាលីនិងសហរដ្ឋអាមេរិកមានមណ្ឌលបោះឆ្នោតនៅកម្រិតទី១ (រដ្ឋ/State)។ ចំពោះបារាំង មានមណ្ឌលបោះឆ្នោតកម្រិត២ (Department) ដោយឡែកតែកម្ពុជាដែលមានមណ្ឌលបោះឆ្នោតកម្រិតភូមិភាគ ដែលជារាជធានី-ខេត្តមួយ និងបណ្ដុំខេត្តច្រើនបញ្ចូលគ្នាដូចមានបរិយាយក្នុងតារាង២។

### តារាង២: កម្រិតដែនដីរដ្ឋបាលសម្រាប់ការជ្រើសតាំងសមាជិកព្រឹទ្ធសភា

| ល.រ | ប្រទេស | កម្រិតដែនដីរដ្ឋបាល |
|---|---|---|
| ១ | អង់គ្លេស និងកាណាដា | ជាតិ |
| ២ | កម្ពុជា | ភូមិភាគ (បណ្តុំខេត្ត) |
| ៣ | អូស្ត្រាលី និងសហរដ្ឋអាម៉េរិក | កម្រិត១ (រដ្ឋ/State) |
| ៤ | បារាំង | កម្រិត២ (Department) |

ប្រភព: https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country

ក្រៅពីមានការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅកម្រិតរដ្ឋបាលដែនដីខុសគ្នាដូចបានរៀបរាប់ខាងលើ ការសិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភានៃប្រទេសបារាំង សហរដ្ឋអាមេរិក កាណាដា អង់គ្លេស និងអូស្ត្រាលី បានបង្ហាញឱ្យឃើញពីវិធីសាស្ត្រ និងប្រព័ន្ធបោះឆ្នោត ផ្សេងៗគ្នាដែលត្រូវបានប្រើប្រាស់សម្រាប់ជ្រើសតាំងសមាជិកព្រឹទ្ធសភា ដើម្បីបំពេញមុខងារតំណាងប្រកបដោយគណនេយ្យភាពចំពោះម្ចាស់ឆ្នោតផងដែរ។

## ៣.២. ប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ប្រទេសមួយចំនួន

ផ្នែកនេះ នឹងលើកអំពីប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់កម្ពុជា បារាំង សហរដ្ឋអាម៉េរិក កាណាដា អង់គ្លេស និងអូស្ត្រាលី ដែលផ្តោតទៅលើការពន្យល់អំពី មុខងារ អាណត្តិ អាសនៈ ប្រព័ន្ធបោះឆ្នោត និងចំនួនមណ្ឌលបោះឆ្នោត។

### ៣.២.១. សភាជាន់ខ្ពស់កម្ពុជា

សភាជាន់ខ្ពស់កម្ពុជា ត្រូវបានបង្កើតឡើងលើកដំបូងនៅឆ្នាំ ១៩៤៧ តាមរយៈមាត្រា៧៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដែលមានឈ្មោះថា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។ ក្រោយមក ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវបានលុបបំបាត់ចោលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ១៩៧៥ (PIC, 2017)។ លុះមកដល់ឆ្នាំ ១៩៩៩ ទើបស្ថាប័ននេះ ត្រូវបានបង្កើតឡើងវិញ ដោយដាក់ឈ្មោះថា ព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភានីតិកាលទី១ទាំងអស់ ត្រូវបានជ្រើសតាំងចេញពីក្នុងចំណោមសមាជិក សមាជិកា នៃគណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភា គឺគណបក្សប្រជាជន គណបក្ស ហ៊្វុន ស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី។ ចាប់តាំងពីនីតិកាលទី២រៀងមក ការជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានធ្វើឡើងតាមរយៈការបោះឆ្នោតអសកលផង និងតែងតាំងផង។ យោងរដ្ឋធម្មនុញ្ញបច្ចុប្បន្នចំនួនសមាជិកព្រឹទ្ធសភា មានចំនួនយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃសមាជិករដ្ឋសភាទាំងមូល។ អ្នកដែលមានបំណងចង់ឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភា ត្រូវមានអាយុតិចបំផុត ៣៥ឆ្នាំ និងជាសមាជិកគណបក្សនយោបាយដែលបានចុះឈ្មោះក្នុងបញ្ជីឈ្មោះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញ បានកំណត់ឱ្យព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិដូចរដ្ឋសភា។ ព្រឹទ្ធសភា មានមុខស្នួលចំនួន ៣ គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង និងមុខងារគាំទ្រចំនួន២ គឺមុខងារការទូតសភា និងមុខងារអភិវឌ្ឍស្ថាប័ន។ វត្តមានព្រឹទ្ធសភាកម្ពុជា មានសារៈសំខាន់ ដើម្បី

តំណាង និងធានាថាផលប្រយោជន៍ជាតិទាំងមូល ត្រូវបានយកចិត្តទុកដាក់ក្នុងដំណើរការនីតិប្បញ្ញត្តិ ព្រមទាំងធ្វើឱ្យមានតុល្យភាពអំណាចក្នុងក្របខ័ណ្ឌនយោបាយកម្ពុជាផងដែរ។

ព្រឹទ្ធសភាមានសមាជិកសរុបចំនួន ៦២រូប និងអាណត្តិ៦ឆ្នាំ ហើយអាចឈរឈ្មោះជាថ្មីឡើងវិញនៅអាណត្តិបន្ទាប់ ប្រសិនបើមានការគាំទ្រ។ អនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ២០១៧ សមាជិកព្រឹទ្ធសភាចំនួន ៥៨រូប ត្រូវឆ្លងកាត់ការបោះឆ្នោតអសកល ដែលមានអង្គបោះឆ្នោត ជាតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង រីឯសមាជិកចំនួន២រូប ត្រូវបានជ្រើសតាំងដោយរដ្ឋសភា និងសមាជិកចំនួន២រូបទៀត ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ (ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា, 2017)។ ការបោះឆ្នោតអសកលនេះ ត្រូវបានរៀបចំឡើងតាមប្រព័ន្ធសមាមាត្រ និងបែងចែកអាសនៈតាម រូបមន្តមធ្យមភាគខ្ពស់បំផុត (D'Hondt Method) មិនគិតសំណល់ចែក (គ.ជ.ប, 2023)។ អាសនៈទាំង ៥៨ ត្រូវបានបែងចែកទៅតាមមណ្ឌលភូមិភាគទាំង ៨ សមាមាត្រចំនួនប្រជាជន និងមានកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ២០១៧។

មណ្ឌលបោះឆ្នោតព្រឹទ្ធសភាទាំង៨ ភូមិភាគ គឺគ្របដណ្តប់ទាំង ២៥ រាជធានី-ខេត្តនៃប្រទេសកម្ពុជា។ ភូមិភាគខ្លះ អាចជារាជធានី ឬខេត្តមួយ ប៉ុន្តែភូមិភាគច្រើនទៀត សុទ្ធតែជាបណ្តុំខេត្តចាប់ពីខេត្តចំនួន ២ ឡើងទៅ។ មណ្ឌលបោះឆ្នោតព្រឹទ្ធសភាកម្រិតភូមិភាគនេះ គឺស្ថិតនៅចន្លោះដែនដីរដ្ឋបាលកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ ដែលខុសពី

រដ្ឋសភា មានមណ្ឌលបោះឆ្នោតនៅកម្រិតដែនដីរដ្ឋបាលទី១ ហើយក៏ខុសប្លែកពីការអនុវត្តនៅបណ្ដាប្រទេសផ្សេងៗទៀតផងដែរ។ ជាទូទៅបណ្ដាប្រទេសនៅលើពិភពលោក រៀបចំការបោះឆ្នោតសភាជាន់ខ្ពស់ នៅរដ្ឋបាលដែនដីកម្រិតជាតិ ឬកម្រិត១ និងកាន់តែតូចទៅដល់ដែនដីកម្រិត២ (កម្រិតស្រុក)។

### ៣.២.២. សភាជាន់ខ្ពស់បារាំង

សភាជាន់ខ្ពស់បារាំង មានឈ្មោះថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ឬភាសាបារាំងហៅថា Sénat ត្រូវបានបង្កើតឡើងដោយច្បាប់ឆ្នាំ១៨៧៥ ក្នុងសម័យសាធារណរដ្ឋទី៣ គឺបានវិវត្តពីក្រុមប្រឹក្សាភិបាល ទៅជាព្រឹទ្ធសភា ដើម្បីតំណាងឱ្យរដ្ឋបាលដែនដីនៅកម្រិតតំបន់តាមការបោះឆ្នោតអសកល(Wikipedia, 2025)។ បច្ចុប្បន្ន នៅក្នុងយុគសម័យសាធារណរដ្ឋទី៥ ដែលបានចាប់ផ្ដើមឡើងតាំងពីឆ្នាំ១៩៥៨ ព្រឹទ្ធសភាបារាំង គឺជាស្ថាប័នដ៏សំខាន់មួយ ដែលបានរួមបញ្ចូលទាំងអត្តសញ្ញាណបែបប្រពៃណីជាមួយនឹងវឌ្ឍនភាពនៃទិដ្ឋភាពនយោបាយរបស់ប្រទេសបារាំង (European Parliament, 2023)។។ តួនាទីចម្បងរបស់ព្រឹទ្ធសភាបារាំង គឺមុខងារតំណាងឱ្យអភិបាលកិច្ចនៅមូលដ្ឋាន (Smith, 2021)។ សមាជិករដ្ឋសភាបារាំងត្រូវឆ្លងកាត់ការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ខណៈដែលសមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតដោយប្រយោល ដែលអង្គបោះឆ្នោត គឺជាសមាជិកក្រុមប្រឹក្សាក្រុងនិងតំណាងមកពីក្រុមប្រឹក្សាផ្សេងៗ (IPEX.eu, 2023)។ ប្រព័ន្ធនេះធានាថាសំឡេងរបស់ប្រជាជននៅតាមមូលដ្ឋាន ជាពិសេសជនបទដាច់ស្រយាល មានអ្នកតំណាងរបស់ខ្លួននៅក្នុងព្រឹទ្ធសភា។

នីតិវិធីបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ប្រែប្រួលអាស្រ័យលើចំនួនអាសនៈ ដែលត្រូវបំពេញនៅក្នុង départements (European Parliament, 2023; IPEX.eu, 2023)។ ជាទូទៅអង្គបោះឆ្នោតរបស់ព្រឹទ្ធសភាបារាំងមានប្រហែល ១៦២ ០០០រូប មកពី départements ចំនួន១០១ (៩៦នៅក្នុងដែនដីបារាំង និង៥ទៀតនៅដែនដីកោះឯនាយសមុទ្ររបស់បារាំង)។ ចំនួនអាសនៈសមាជិកព្រឹទ្ធសភាមកពី départements គឺអាស្រ័យលើដង់ស៊ីតេប្រជាជន។ ចាប់តាំងពីឆ្នាំ២០១១មក ព្រឹទ្ធសភាបារាំង មានសមាជិកចំនួន៣៤៨រូប ដែលត្រូវឆ្លងកាត់ប្រព័ន្ធបោះឆ្នោត២ជុំ។ នៅក្នុងចំណោមសមាជិកព្រឹទ្ធសភាទាំង៣៤៨រូប គឺមានសមាជិក ៣២៦រូប ដែលតំណាងឱ្យ départements, សមាជិកព្រឹទ្ធសភា៨រូប ផ្សេងទៀតតំណាងឱ្យដែនដីកោះរបស់បារាំង និងសមាជិកព្រឹទ្ធសភា១២រូប ផ្សេងទៀតតំណាងឱ្យពលរដ្ឋបារាំងដែលរស់នៅក្រៅប្រទេសបារាំង (Sénat, 2024; Wikipedia, 2023)។ សម្រាប់ départements ដែលមានអាសនៈចំនួន៣ឬច្រើនត្រូវប្រើប្រព័ន្ធបញ្ជីតំណាងតាមបែបសមាមាត្រ (IPEX.eu, 2023)។

សមាជិកព្រឹទ្ធសភាមានអាណត្តិរយៈពេល៦ឆ្នាំ ដោយសមាជិកពាក់កណ្ដាលរបស់ព្រឹទ្ធសភា ត្រូវបានបោះឆ្នោតជ្រើសរើសរៀងរាល់៣ឆ្នាំម្ដង ដើម្បីធ្វើឱ្យមានតុល្យភាពនៃដំណើរការ និងការផ្លាស់ប្ដូរនៅក្នុងស្ថាប័ន។ សិទ្ធិឈរឈ្មោះបោះឆ្នោតជាសមាជិកព្រឹទ្ធសភា តម្រូវឱ្យបេក្ខជនម្នាក់ៗមានអាយុយ៉ាងតិច២៤ឆ្នាំ (IPEX.eu, 2023) ។ ការផ្លាស់ប្ដូរសំខាន់ៗនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសបារាំង ជាពិសេសការផ្លាស់ប្ដូរពី "provinces" ទៅ "regions" បានធ្វើឱ្យមានការផ្លាស់ប្ដូររចនាសម្ព័ន្ធអាសនៈរបស់ព្រឹទ្ធសភាផងដែរ (Wikipedia, 2023) ។ កាលពីមុន

របចនាសម្ព័ន្ធរដ្ឋបាលដែនដីរបស់បារាំង ត្រូវបានបែងចែកនៅកម្រិត "provinces" ក្រោយមកត្រូវបានផ្លាស់ប្តូរទៅជា *départements* បន្ទាប់ពីបដិវត្តន៍ និងក្រោយមកទៀតក៏ប្តូរទៅជា "regions" ជាពិសេសក្នុងរបប Vichy (1940-1944) ។ នៅឆ្នាំ២០១៦ បារាំងបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងដែនដីម្តងទៀត ដោយបានកាត់បន្ថយចំនួន regions ពី ២២ មក១៣ ដើម្បីបង្កើនប្រសិទ្ធភាពរដ្ឋបាល (Sénat, 2024; Wikipedia, 2023)។ ការវិវត្តនេះ កំណត់ទំនាក់ទំនងរបស់ព្រឹទ្ធសភាជាមួយប្រព័ន្ធវិមជ្ឈការ និងអភិបាលកិច្ចមូលដ្ឋាន ចំនួនសមាជិកព្រឹទ្ធសភាបានវិវត្តទៅតាមពេលវេលា កាលពីមុនមានកំណែទម្រង់មានសមាជិកត្រឹម៣២១រូប ក្រោយមកចំនួនសមជិកបានកើនឡើងដល់៣៣១រូប នៅចន្លោះឆ្នាំ២០០៤ និង ៣៤៣រូបនៅក្នុងឆ្នាំ២០០៨ និង ៣៤៨រូប ចាប់តាំងពីឆ្នាំ២០១១។ តាមរយៈរចនាសម្ព័ន្ធ និងដំណើរការបោះឆ្នោត ព្រឹទ្ធសភានៅតែបន្តសម្របខ្លួន ទៅតាមកំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលដែនដីរបស់បារាំងជានិច្ច ដើម្បីធានាថាព្រឹទ្ធសភានៅតែបន្តជាស្ថាប័នតែមួយគត់ តំណាងឱ្យផលប្រយោជន៍ចម្រុះនៃសហគមន៍ដែនដីរបស់ប្រទេសបារាំង ។

### ៣.២.៣. សភាជាន់ខ្ពស់ចក្រភពអង់គ្លេស

សភាជាន់ខ្ពស់ចក្រភពអង់គ្លេស ហៅថាសភាអភិជន ជាភាសាអង់គ្លេសហៅថា House of Lords ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨០១ មានតួនាទី ត្រួតពិនិត្យច្បាប់ តាមដានការអនុវត្តរបស់រដ្ឋាភិបាល និងអង្កេតគោលនយោបាយសាធារណៈ(UK Parliament, 2025)។ សភាអភិជន បានវិវត្តពីក្រុមប្រឹក្សាអភិជន (Council of Nobles) ទៅជាស្ថាប័នសភាជាន់ខ្ពស់មួយ ដែលសមាជិកភាគច្រើនរបស់ខ្លួនត្រូវបាន

ជ្រើសតាំងពីចំណោមអភិជន បព្វជិត និងឥស្សរជនឆ្នើមៗនៅក្នុងសង្គមអង់គ្លេស មានដូចជា អភិជនតវង្សត្រកូល អភិជនឆ្នើម សម្តេចសង្ឃរាជ (Archbishops) និងបុគ្គលឆ្នើមក្នុងអាជីពដែលទទួលបានការគោរពពីសង្គម និងមានអាណត្តិមួយជីវិត (UK Parliament, 2025)។

គិតត្រឹមថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ សភាអភិជនមានសមាជិកសរុប៨៥០រូប (UK Parliament, 2025) ប៉ុន្តែកំពុងស្ថិតក្នុងតំណែង (sitting members) ត្រឹម ៨២៥រូបប៉ុណ្ណោះ ដែលចំនួនសមាជិកនេះមានការប្រែប្រួលជាប្រចាំ។ ការតែងតាំងសមាជិកសភាអភិជន ធ្វើឡើងតាមប្រភពចំនួន ៣៖

- សមាជិកមកពីប្រភពគណបក្សនយោបាយ
  - គណបក្សនយោបាយរៀបចំបញ្ជីសមាជិករបស់ខ្លួន
  - សំណើពីនាយករដ្ឋមន្ត្រី ដែលលាលែងពីតំណែង
  - សមាជិកសភាជាន់ទាប ដែលចប់តំណែង
  - រដ្ឋាភិបាលប្រកាសជ្រើសតាំងសមាជិកព្រឹទ្ធសភាតាមការចាំបាច់
- សមាជិកមិនពាក់ព័ន្ធនយោបាយ
  - គណៈកម្មការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់
  - ការជ្រើសតាំងដោយសាធារណៈមតិ
  - សាមីជន អាចដាក់ពាក្យទៅគណៈកម្មការជ្រើសតាំងសមាជិកសភាអភិជននេះបាន
- សមាជិកតាមតំណវង្សត្រកូល និងបព្វជិតជាន់ខ្ពស់

- បច្ចុប្បន្នមានសមាជិកសភាជាន់ខ្ពស់តាមតំណវង្ស ត្រកូលចំនួន ៩២ រូប ដែលពួកគេ អាចជ្រើសរើស បេក្ខជននៅក្នុងបណ្តាសមាជិកនៃវង្សត្រកូលរៀងខ្លួន
- បព្វជិតជាន់ខ្ពស់ (ច្រើនបំផុត ២៦ រូប) មកពីព្រះវិហារ គ្រិស្តនៅអង់គ្លេស អាចត្រូវបានជ្រើសតាំងជាសមាជិក សភាអភិជន

អំណាចរបស់សភាអភិជន ត្រូវបានកំណត់ដោយច្បាប់សភា (Act of Parliament)។ សភានេះ អាចពន្យារពេល អនុម័តច្បាប់បាន ប៉ុន្តែគ្មានអំណាចរារាំងច្បាប់ បាននោះទេ (UK Parliament, 2024.; Russell, M.2023) ។ កន្លងមក ធ្លាប់មានការប៉ុនប៉ងជាច្រើនដង ដើម្បី ធ្វើកំណែទម្រង់សភាអភិជន ដូចជាសំណើដកសមាជិកភាព ពីការស្នង តំណែងតាមវង្សត្រកូល ដែលភាគច្រើនក្នុងឆ្នាំ១៩៩៩ (Wikipedia, 2023)។ មតិរិះគន់ និងការដេញដោលមតិ អំពីលក្ខណសម្បត្តិរបស់ សមាជិកសភាអភិជន ដែលមិនឆ្លងកាត់ការបោះឆ្នោត គឺដើរផ្ទុយពី លទ្ធិប្រជាធិបតេយ្យ ហើយកន្លងមកសភាអភិជននេះ មានការគាំទ្រពី សាធារណជនក្នុងរង្វង់៣០%តែប៉ុណ្ណោះ (Transparency International UK, 2024)។ លើសពីនេះ ក៏មានសំណើឱ្យកែទម្រង់ទៅ ជាសភាកូនកាត់ ឬសភាអភិជនដែលឆ្លងកាត់ការបោះឆ្នោតទាំងស្រុងតែ ម្តង។ នៅក្នុងនោះ គណបក្សការងារ (Labor Party) បានស្នើឱ្យដក សមាជិកដែលស្នងតំណែងតាមវង្សត្រកូលចេញទាំងអស់ ។ ការមិនឆ្លង កាត់ការបោះឆ្នោតរបស់សភាអភិជន ផ្តល់អាទិភាពដល់អ្នកជំនាញ ប៉ុន្តែ ធ្វើឱ្យមានកង្វះការទទួលខុសត្រូវចំពោះសាធារណជន ដែលតែងតែរង

ការរិះគន់ចំពោះឱនភាពប្រជាធិបតេយ្យ (Wikipedia, 2023; Transparency International UK, 2024)។

### ៣.២.៤. សភាជាន់ខ្ពស់សហរដ្ឋអាម៉េរិក

សភាជាន់ខ្ពស់សហរដ្ឋអាម៉េរិក ហៅថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៧៨៩ ដើម្បីធ្វើឱ្យមានតុល្យភាពអំណាច រវាងសភាជាន់ទាប ឬសភាតំណាងរាស្ត្រ (Swearingen&Ripberger, 2011; Druckman, 2004)។ ដំបូងឡើយ ព្រឹទ្ធសភាអាម៉េរិក ឆ្លងកាត់ការបោះឆ្នោតអសកល ប៉ុន្តែបន្ទាប់ពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១៧ រួចមក នៅឆ្នាំ១៩១៣ ទើបប្តូរមកជាការបោះឆ្នោតសកលវិញ ដែលបានឆ្លុះបញ្ចាំងពីកំណែទម្រង់លទ្ធិប្រជាធិបតេយ្យ (U.S. Senate, 2025)។ រដ្ឋនីមួយៗក្នុងចំណោមរដ្ឋទាំង៥០ ត្រូវបានតំណាងដោយសមាជិកព្រឹទ្ធសភាចំនួន២រូប ដែលធ្វើឱ្យសមាជិកសរុបមានចំនួន១០០រូប តាមការបោះឆ្នោតសកលទូទាំងសហរដ្ឋអាម៉េរិក។ ប្រព័ន្ធនេះ ធានាឱ្យរដ្ឋនីមួយៗ មានចំនួនសមាជិកស្មើៗគ្នា ដោយមិនគិតពីចំនួនប្រជាជន ឬទំហំរដ្ឋឡើយ (Swearingen&Ripberger, 2011; Wikipedia, 2023) ។

សមាជិកព្រឹទ្ធសភាអាម៉េរិកទាំង១០០រូប មានអាណត្តិ៦ឆ្នាំ ដែលសមាជិកមួយភាគបី (១/៣) ត្រូវបោះឆ្នោតជ្រើសរើសរៀងរាល់២ឆ្នាំម្តងតាមការបោះឆ្នោតសកល ដោយប្រើប្រព័ន្ធឈ្នះភាគច្រើនដោយប្រៀប (ឯកត្តនាម) (FPTP) (Druckman, 2004) ។សមាជិកព្រឹទ្ធសភាមានអំណាចសំខាន់ៗ រួមមានការធ្វើច្បាប់ ការអនុម័តសន្ធិសញ្ញា និងការ

អនុម័តឯកភាព លើការតែងតាំងសមាសភាពដឹកនាំ នៅអង្គនីតិប្រតិបត្តិ (Druckman, 2004) ។

ដើម្បីមានសិទ្ធិឈរឈ្មោះជាសមាជិកព្រឹទ្ធសភា បេក្ខជនម្នាក់ៗ ត្រូវតែមានអាយុយ៉ាងតិច៣០ឆ្នាំ ជាពលរដ្ឋអាម៉េរិកយ៉ាងហោចណាស់ ៩ឆ្នាំ និងជាអ្នករស់នៅក្នុងរដ្ឋដែលពួកគេឈរឈ្មោះ (Druckman, 2004; Wikipedia, 2023)។ ព្រឹទ្ធសភាអាម៉េរិក មានអំណាច ផ្តាច់មុខ រួមមានសិទ្ធិអំណាចក្នុងការអនុម័ត ឬបដិសេធការតែងតាំងប្រធានាធិបតី និងតុលាការ និងការផ្តល់សច្ចាប័នលើសន្ធិសញ្ញា ដែលបានចរចាដោយ អង្គប្រតិបត្តិ។ ព្រឹទ្ធសភា ក៏មានអំណាចផ្តាច់មុខក្នុងការជំនុំជម្រះលើការ ចោទប្រកាន់ដកតួនាទី ឬដកសេចក្តីទុកចិត្ត ដោយដើរតួជាគណៈវិនិច្ឆ័យ (Jury) និងចៅក្រម(Swearingen & Ripberger, 2011; U.S. Senate, 2024)។ ប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាអាម៉េរិក ពិតជាធានាឱ្យមានភាពស្មើ គ្នារវាងរដ្ឋនីមួយៗ ដោយមិនគិតពីទំហំរដ្ឋទាំងទឹកដី សេដ្ឋកិច្ច និងចំនួន ប្រជាជន ដែលបង្កើនគណនេយ្យភាពចំពោះអ្នកបោះឆ្នោតនៅគ្រប់រដ្ឋ ទាំងអស់ ប៉ុន្តែបង្កឱ្យមានបញ្ហាវិសមភាព និងអសមធម៌រវាងរដ្ឋតូចនិងរដ្ឋ ធំ ក្នុងការសម្រេចលើបញ្ហាជាក់លាក់ណាមួយ។ ចំនួនអ្នកទៅបោះឆ្នោត ព្រឹទ្ធសភាជាមធ្យមមានប្រហែលពី៥០-៦០% ក្នុងជុំបោះឆ្នោតនីមួយៗ (U.S. Senate, 2024)។

### ៣.២.៥. សភាជាន់ខ្ពស់កាណាដា

សភាជាន់ខ្ពស់កាណាដា ហៅថាព្រឹទ្ធសភា ជាភាសាអង់គ្លេស ហៅថា Senate ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៦៧ មានតួនាទីជា "ការគិតលើកទី២ប្រកបដោយភាពសុក្រឹត" សម្រាប់អង្គនីតិប្បញ្ញត្តិ

(Gidda, 2018; Hamilton, 2021) ។ មុខងារចម្បងរបស់ព្រឹទ្ធសភាកាណាដា គឺពិនិត្យ និងធ្វើវិសោធនកម្មច្បាប់ដែលអនុម័តដោយសភាជាន់ទាប ដើម្បីធានាថាច្បាប់ទាំងឡាយ ត្រូវបានគិតគូរពិចារណាយ៉ាងប្រុងប្រយ័ត្នមុនពេលអនុម័ត។ ព្រឹទ្ធសភា មានតួនាទីតំណាងក្នុងតំបន់ដើម្បីរក្សាតុល្យភាពអំណាចជាមួយសភាជាន់ទាប ធ្វើឱ្យដំណើរការនីតិប្បញ្ញត្តិ មានតុល្យភាពជាងមុន (Hamilton, 2021; Parliament of Canada, n.d.)។ តាមរយៈគណៈកម្មាធិការរបស់ខ្លួន ព្រឹទ្ធសភាអាចតាមដាន និងអង្កេតលើបញ្ហាជាតិ ជំរុញការសម្រេចចិត្តជាគោលនយោបាយ ផ្អែកលើព័ត៌មានឆ្លុះបញ្ចាំងទស្សនៈចម្រុះ(Gidda, 2018; Hamilton, 2021) ។

ព្រឹទ្ធសភាមានសមាជិកចំនួន១០៥រូប ដែលត្រូវបានតែងតាំងតាមមុខជំនាញវិជ្ជាជីវៈ ដូចជាអ្នកជំនួញ សាស្ត្រាចារ្យ អ្នកវិទ្យាសាស្ត្រ តុលាការ ថ្នាក់ដឹកនាំមូលដ្ឋាន សង្គមស៊ីវិល អ្នកកីឡាអាជីព ដែលមានបទពិសោធ និងជោគជ័យក្នុងជីវិត។ ពួកគេត្រូវបានជ្រើសតាំងដោយអគ្គទេសាភិបាល តាមសំណើរបស់នាយករដ្ឋមន្ត្រី (Gidda, 2018; The Canadian Encyclopedia, 2022)។ អាសនៈព្រឹទ្ធសភានេះ ត្រូវបានកំណត់តាមរដ្ឋធម្មនុញ្ញ[4]៖

- តំបន់កេបិចមាន ២៤អាសនៈ
- តំបន់អនតារីយ៉ូមាន ២៤អាសនៈ

[4] About the Senate - Canada.ca https://share.google/2djIokr9lWWjR37qN

- តំបន់ខេត្តភាគខាងលិច (Albertam, British Columbia, Manitoba, and Saskatchewan)មាន ២៤អាសនៈ
- តំបន់ជាប់សមុទ្រ (ខេត្ត New Brunswick មាន១០ អាសនៈ, ខេត្ត Nova Scotia មាន១០អាសនៈ និង Prince Edward Island មាន ៤ អាសនៈ
- តំបន់ Newfoundland និងតំបន់ Labrador មាន៦ អាសនៈក្នុង ១តំបន់
- ដែនដី Yukon, Northwest, Nunavut មាន១អាសនៈ ក្នុង១ដែនដី។

បេក្ខជនឈរឈ្មោះ ជាសមាជិកព្រឹទ្ធសភាកាណាដា ត្រូវតែជាពលរដ្ឋកាណាដា ដែលមានអាយុយ៉ាងតិច៣០ឆ្នាំ ជាម្ចាស់អចលនទ្រព្យដែលមានតម្លៃយ៉ាងតិច ៤ ០០០ដុល្លារអាម៉េរិក និងត្រូវតែជាប្រជាជនមានទីលំនៅក្នុងខេត្ត ឬទឹកដីដែលពួកគេឈរឈ្មោះ។ សមាជិកព្រឹទ្ធសភានឹងកាន់តំណែងរហូតដល់ចូលនិវត្តន៍ ដែលត្រូវបានកំណត់ត្រឹមអាយុ៧៥ឆ្នាំ (Gidda, 2018; The Canadian Encyclopedia, 2022)។

ដំណើរការតែងតាំងសមាជិកព្រឹទ្ធសភាកាណាដា នៅតែជាប្រធានបទរសើប និងរងការរិះគន់ និងជជែកវែកញែកជេញដោលជាបន្តបន្ទាប់ ជាពិសេសទាក់ទងនឹងភាពស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ (The Canadian Encyclopedia, 2022)។ ការរិះគន់នេះគឺផ្តោតទៅលើចំណុចដែលថា សមាជិកព្រឹទ្ធសភា មានទំនាក់ទំនងជាប្រវត្តិសាស្ត្រជាមួយគណបក្សនយោបាយ ពោលគឺសមាជិកព្រឹទ្ធសភាបម្រើ

ប្រយោជន៍នយោបាយច្រើនជាងប្រយោជន៍ប្រជាជន។ ទើបថ្មីៗនេះ មានកំណែទម្រង់ប្រព័ន្ធតែងតាំងសមាជិកព្រឹទ្ធសភា ដើម្បីបង្កើតភាពអ-ព្យាក្រឹតគណបក្សនយោបាយ និងមិនលម្អៀងបន្ថែមទៀត ដោយបញ្ចូលបន្ថែមនូវក្រុមនានាដូចជា ក្រុមសមាជិកព្រឹទ្ធសភាឯករាជ្យ និងគណបក្សអភិរក្ស ។ អ្នករិះគន់ពីប្រព័ន្ធតែងតាំងសមាជិកព្រឹទ្ធសភា ទាមទារឱ្យមានការបោះឆ្នោតដើម្បីឱ្យសមាជិកទាំងនោះក្លាយជាអ្នកតំណាង តាមបែបប្រជាធិបតេយ្យ ខណៈពេលដែលមតិមួយចំនួនទៀត សង្កត់ធ្ងន់លើសារៈសំខាន់ ដែលព្រឹទ្ធសភាត្រូវតែការពារផលប្រយោជន៍តំបន់ដែលខ្លួនតំណាង និងផលប្រយោជន៍ក្រុមភាគតិច (Hamilton, 2021; Parliament of Canada., n.d.) ។ ទោះបីជាប្រឈមមុខនឹងការត្រួតពិនិត្យ និងរិះគន់លើគណនេយ្យភាពក៏ដោយ ក៏ព្រឹទ្ធសភានៅតែជាស្ថា-ប័នសំខាន់មួយនៅក្នុងអភិបាលកិច្ចកាណាដា ដែលតំណាងឱ្យសំឡេងចម្រុះ និងការសម្របខ្លួនទៅនឹងទិដ្ឋភាពនយោបាយដែលកំពុងវិវត្ត។

### ៣.២.៦. សភាជាន់ខ្ពស់អូស្ត្រាលី

សភាជាន់ខ្ពស់អូស្ត្រាលី ហៅថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩០១ តាមរយៈការបោះឆ្នោតសកល (Australian Parliament,n.d)។ ព្រឹទ្ធសភាដើរតួនាទីសំខាន់តំណាងឱ្យប្រជាជនអូស្ត្រាលី បង្កើតច្បាប់ ឬច្រានចោលសេចក្តីព្រាងច្បាប់ ដែលជាការឆ្លុះបញ្ចាំងពីភាពតំណាង តាមប្រព័ន្ធប្រជាធិបតេយ្យ (Blom, 2024)។ នៅក្នុងការបោះឆ្នោតនាពេលថ្មីៗ មានអ្នកទៅបោះឆ្នោតលើសពី៩០% នៅក្នុងតំបន់មួយចំនួន ដែលបង្ហាញពីការចូលរួមពីសាធារណជនដ៏រឹងមាំ (The Australia Institute, 2021)។ រដ្ឋធម្មនុញ្ញអូស្ត្រាលី បានបង្កើតសភាពីរថ្នាក់ ដោយយកគំរូតាមព្រឹទ្ធសភាសហរដ្ឋ

អាម៉េរិក ផ្តល់អាសនៈស្មើៗគ្នាសម្រាប់រដ្ឋនីមួយៗ និងផ្តល់អំណាចស្មើរតែដូចគ្នា ជាមួយសភាជាន់ទាប (Wikipedia, 2023)។ ព្រឹទ្ធសភាមានសមាជិកចំនួន៧៦រូប ដែលក្នុងមួយរដ្ឋមាន១២រូប និង២រូបក្នុងមួយដែនដី។ សមាជិកព្រឹទ្ធសភា ដែលតំណាងឱ្យរដ្ឋនីមួយៗ មានអាណត្តិ៦ឆ្នាំ រីឯសមាជិកតំណាងឱ្យដែនដីមានអាណត្តិត្រឹម ៣ឆ្នាំប៉ុណ្ណោះ។ សមាជិកពាក់កណ្តាលនៃព្រឹទ្ធសភាអូស្ត្រាលី ត្រូវបានបោះឆ្នោតជ្រើសរើសរៀងរាល់៣ឆ្នាំម្តង (Parliament of Australia, 2025)។

សមាជិកព្រឹទ្ធសភាអូស្ត្រាលី ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតសកល ដោយប្រើប្រព័ន្ធតំណាងសមាមាត្រ (Blom, 2024)។ ពាក់កណ្តាលនៃអាសនៈរបស់ព្រឹទ្ធសភា ត្រូវបានបោះឆ្នោតជ្រើសរើស ស្របគ្នាជាមួយនឹងការបោះឆ្នោតសភាតំណាងរាស្ត្រ ដែលត្រូវបានគេស្គាល់ថាជាការបោះឆ្នោតពាក់កណ្តាលព្រឹទ្ធសភា (Wikipedia, 2023)។ ប្រព័ន្ធបោះឆ្នោតសកលបែបសមាមាត្ររបស់ព្រឹទ្ធសភាអូស្ត្រាលី ធានានូវភាពតំណាង បង្កើនគណនេយ្យភាពចំពោះអ្នកបោះឆ្នោត និងភាពចម្រុះនៃសមាជិកព្រឹទ្ធសភា (The Australia Institute, 2021)។

ព្រឹទ្ធសភាអូស្ត្រាលី គឺជាស្ថាប័នត្រួតពិនិត្យ និងតាមដានការអនុវត្តរបស់រដ្ឋាភិបាលដ៏មានឥទ្ធិពលនាពេលបច្ចុប្បន្ន។ ប្រព័ន្ធតំណាងសមាមាត្រ និងឆ្លងកាត់ការបោះឆ្នោតជាសកល ផ្តល់ឱកាសសម្រាប់បេក្ខជនឈរឈ្មោះឯករាជ្យ និងបេក្ខជនមកពីគណបក្សតូចៗ ចូលរួមក្នុងការបោះឆ្នោត។ ប៉ុន្មានទសវត្សរ៍ថ្មីៗនេះ គណបក្សកាន់អំណាច មិនមានសំឡេងភាគច្រើននៅក្នុងព្រឹទ្ធសភានោះទេ ទើបមិនអាចបោះឆ្នោតបដិសេធ ឬធ្វើវិសោធនកម្មច្បាប់តាមបំណងរបស់រដ្ឋាភិបាលបាន។ ប្រព័ន្ធដែលមានគណៈកម្មាធិការធំ

ហើយសកម្ម អនុញ្ញាតឱ្យសមាជិកព្រឹទ្ធសភាអាចសាកសួរបានស៊ីជម្រៅ អំពីគោលនយោបាយ និងពិនិត្យមើលរបៀបរបបនៃការអនុវត្តច្បាប់ និង គោលនយោបាយ ដែលគ្រប់គ្រងដោយរដ្ឋមន្ត្រី និងមន្ត្រីសាធារណៈ (Wikipedia, 2023)។

## តារាងទី៣: ប្រៀបធៀបប្រព័ន្ធព្រឹទ្ធសភា/សភាជាន់ខ្ពស់ នៃប្រទេសនៅលោកខាងលិច

| បរិយាយ | កម្ពុជា | បារាំង | អាម៉េរិក | អង់គ្លេស | កាណាដា | អូស្ត្រាលី |
|---|---|---|---|---|---|---|
| អាសនៈ | ៦២ | ៣៤៨ | ១០០ | ៨៥០[5] | ១០៥ | ៧៦ |
| អាណត្តិ (ឆ្នាំ) | ៦ | ៦ (១/២ បោះឆ្នោតរាល់៣ឆ្នាំ) | ៦ (១/៣ បោះឆ្នោតរាល់២ឆ្នាំ) | ពេញមួយជីវិត | រហូតអាយុ ៧៥ឆ្នាំ | - ៦ (State) ១/២បោះឆ្នោតរាល់៣ឆ្នាំ - ២ (Territory) |
| សមាជិកព្រឹទ្ធសភា | - បោះឆ្នោតអសកល ៥៨ - ចាត់តាំង / ជ្រើសតាំង ៤ | បោះឆ្នោតអសកល | បោះឆ្នោតសកល | តែងតាំង | តែងតាំង | បោះឆ្នោតសកល |
| មណ្ឌលបោះឆ្នោត | កម្រិតភូមិភាគ | ដែនដីកម្រិត២ | ដែនដីកម្រិត១ | N/A (ជ្រើសតាំង) | N/A (ជ្រើសតាំង) | ដែនដីកម្រិត១ |
| ចំនួនមណ្ឌលតំណាង | ៨ | ១០១ departments | ៥០ រដ្ឋ | N/A | ៤ ភូមិភាគ និង ៣ ដែនដី | ៦រដ្ឋ និង ២ ដែនដី |

**Sources:** Inter-Parliamentary Union (IPU) https://data.ipu.org/ , Constitute Project https://www.constituteproject.org/ , and Wikipedia https://en.wikipedia.org/wiki/D%27Hondt_method#cite_note-25

### ៣.៣. ការវិភាគប្រៀបធៀប

ការសិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោត និងរៀបចំនៃសភាជាន់ខ្ពស់ នៃប្រទេសបារាំង ចក្រភពអង់គ្លេស សហរដ្ឋអាម៉េរិក កាណាដា អូស្ត្រាលី

[5] ចំនួន៨៥០នេះ គិតត្រឹមថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៥ ហើយចំនួននេះមានការប្រែប្រួល។

និងកម្ពុជា បានបង្ហាញពីការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា ក្នុងការជ្រើសរើសសមាជិកសភាជាន់ខ្ពស់ ដែលមានឥទ្ធិពលដល់មុខងារតំណាង និងគណនេយ្យភាព។

## ៣.៣.១. ភាពតំណាង និងគណនេយ្យភាព

ភាពតំណាងរបស់សមាជិកសភាជាន់ខ្ពស់ សំដៅលើដំណើរការដែលសមាជិកសភាជាន់ខ្ពស់ សម្តែងមតិ និងធ្វើសកម្មភាពផ្សេងៗ ដើម្បីការពារផលប្រយោជន៍ប្រជាជន ជាពិសេសអ្នកបោះឆ្នោត ឬអង្គបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន ឬអ្នកដែលបានតែងតាំងខ្លួន។ រីឯគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ សំដៅលើការទទួលខុសត្រូវ ឬការឆ្លើយតបរបស់សមាជិកសភាជាន់ខ្ពស់ម្នាក់ៗ ចំពោះសាធារណៈ ជាពិសេសអង្គបោះឆ្នោត លើបញ្ហាច្បាប់ សកម្មភាព និងការសម្រេចចិត្តនានារបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពតំណាង ឬគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ សមាជិកសភាជាន់ខ្ពស់ តំណាងឱ្យប្រជាជនទូទាំងប្រទេស ប៉ុន្តែពួកគាត់តែងយកចិត្តទុកដាក់ជាចម្បងចំពោះអ្នកបោះឆ្នោត អង្គបោះឆ្នោត ក្នុងមណ្ឌលរបស់គាត់ ឬអ្នកតែងតាំងគាត់។ ជាទូទៅ សមាជិកព្រឹទ្ធសភា ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតសកល ការបោះឆ្នោតអសកល និងការតែងតាំង។

### ភាពតំណាង

សមាជិកព្រឹទ្ធសភានៅអូស្ត្រាលី និងអាម៉េរិក កើតចេញពីការបោះឆ្នោតសកល ដែលភាពតំណាងរបស់ពួកគាត់ គឺស្ថិតនៅក្នុងដែនដីរដ្ឋបាលកម្រិត១។ ភាពតំណាងរបស់សមាជិកព្រឹទ្ធសភានៅប្រទេសទាំង

ពីរ មិនអាស្រ័យលើចំនួនអ្នកបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួននោះទេ។ នៅសហរដ្ឋអាម៉េរិក រដ្ឋនីមួយៗ មានសមាជិកព្រឹទ្ធសភា ២រូប មិនអាស្រ័យទៅលើចំនួនអ្នកបោះឆ្នោតដែលមាននៅក្នុងរដ្ឋនីមួយៗនោះទេ។ រីឯ នៅប្រទេសអូស្ត្រាលីវិញ ក៏មានភាពស្រដៀងគ្នាដែរ ពោលគឺរដ្ឋនីមួយៗ មានសមាជិកព្រឹទ្ធសភាចំនួន ១២រូប លើកលែងតែដែនដីចំនួន ២ ដែលដែនដីនីមួយៗមានសមាជិកព្រឹទ្ធសភាចំនួន ២រូប តែប៉ុណ្ណោះ។

ភាពតំណាងរបស់សមាជិកព្រឹទ្ធសភានៅកម្ពុជា និងនៅបារាំង គឺអាស្រ័យលើចំនួនអង្គបោះឆ្នោត នៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗ។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅកម្ពុជា និងបារាំង ធ្វើឡើងជាអសកល។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាកម្ពុជា ធ្វើតាមភូមិភាគ ដែលជាបណ្តុំនៃខេត្ត ពោលគឺនៅចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ រីឯនៅបារាំងវិញ គឺស្ថិតនៅដែនដីរដ្ឋបាលកម្រិត ២ (Departement = កម្រិតស្រុកនៅកម្ពុជា)។

ចំណែកឯសមាជិកសភាជាន់ខ្ពស់អង់គ្លេស និងកាណាដា មិនកើតចេញពីការបោះឆ្នោតសកល ឬអសកលនោះទេ ប៉ុន្តែកើតចេញពីការតែងតាំង។ ហេតុដូច្នេះ ភាពតំណាងរបស់គាត់មិនផ្តោតលើមណ្ឌលបោះឆ្នោតណាមួយជាក់លាក់នោះទេ ពោលគឺមានភាពទូលំទូលាយ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់តំណាងឱ្យជំនាញវិជ្ជាជីវៈ អ្នកជំនួញ អ្នកវិទ្យាសាស្ត្រ សាស្ត្រាចារ្យ កីឡាករអាជីព វង្សត្រកូលអភិជន និងបញ្ញវន្តជាន់ខ្ពស់ ដែលមានបទពិសោធខ្ពស់ និងមានភាពជោគជ័យ

ក្នុងជីវិត ដែលរួមចំណែកយ៉ាងសំខាន់ក្នុងតួនាទីប្រឹក្សាយោបល់ និងត្រួតពិនិត្យច្បាប់។

## គណនេយ្យភាព

គណនេយ្យភាព របស់សមាជិកសភាជាន់ខ្ពស់ទាំងអស់ខាងលើមានលក្ខណៈខុសគ្នា។ ព្រឹទ្ធសភា ដែលអនុវត្តប្រព័ន្ធបោះឆ្នោតសកលដូចនៅសហរដ្ឋអាមេរិក និងអូស្ត្រាលី ទទួលខុសត្រូវផ្ទាល់ចំពោះអ្នកបោះឆ្នោត ហើយធានានូវភាពស្របច្បាប់ តាមលទ្ធិប្រជាធិបតេយ្យ (Druckman, 2004; Blom, 2024)។ ព្រឹទ្ធសភាដែលអនុវត្តប្រព័ន្ធបោះឆ្នោតអសកល ដូចជាព្រឹទ្ធសភាបារាំង និងកម្ពុជា មានទំនួលខុសត្រូវចំពោះមន្ត្រីមូលដ្ឋាន ហើយធ្វើឱ្យមានតុល្យភាពឥទ្ធិពល ពីមូលដ្ឋានជាមួយនឹងគោលនយោបាយជាតិ (Watson, 2024) ។ ការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ដោយការតែងតាំង ដូចនៅចក្រភពអង់គ្លេស និងកាណាដា ផ្តល់អាទិភាព និងតម្លៃដល់អ្នកជំនាញវិជ្ជាជីវៈ អភិជន បព្វជិតជាន់ខ្ពស់ និងបុគ្គលដែលមានភាពជោគជ័យក្នុងជីវិត។ ប្រព័ន្ធនេះ ក៏ផ្តោតសំខាន់លើការធានានិរន្តរភាពនៃព្រឹទ្ធសភា ជាជាងលើគណនេយ្យភាពតាមការបោះឆ្នោត។ ជារឿយៗ ការតែងតាំងតាមបែបព្រឹទ្ធសភាកាណាដា និងសភាអភិជនអង់គ្លេស តែងរងការរិះគន់ ដោយសារការធ្លាក់ចុះនៃប្រជាធិបតេយ្យ (Russell, 2013; Hamilton, 2021)។

ការជ្រើសរើសសមាជិកព្រឹទ្ធសភាតាមរយៈការបោះឆ្នោតសកលដូចនៅសហរដ្ឋអាមេរិក និងអូស្ត្រាលី ធានានូវគណនេយ្យភាពសមាជិកព្រឹទ្ធសភាចំពោះអ្នកបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួនដែលជាទូទៅមានចំនួនអ្នកបោះឆ្នោតច្រើន។ រីឯការជ្រើសរើសសមាជិក

ព្រឹទ្ធសភាតាមរយៈការបោះឆ្នោតអសកល ដូចនៅកម្ពុជា និងបារាំង ធ្វើឱ្យគណនេយ្យភាពសមាជិកព្រឹទ្ធសភាមានត្រឹមចំពោះអង្គបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន ដែលជាទូទៅមានចំនួនអ្នកបោះឆ្នោតតិចជាងការបោះឆ្នោតសកល។ ចំពោះការជ្រើសរើសសមាជិកសភាជាន់ខ្ពស់តាមរយៈការតែងតាំង ដូចនៅចក្រភពអង់គ្លេស និងកាណាដា ធ្វើឱ្យគណនេយ្យភាពសមាជិកសភាជាន់ខ្ពស់មានត្រឹមចំពោះអ្នកតែងតាំងរបស់ខ្លួន ដែលធ្វើឱ្យគណនេយ្យភាពជាមួយប្រជាជននៅមានកម្រិត។

## ៣.៣.២. ប្រសិទ្ធភាពគណនេយ្យភាពសភា

ប្រសិទ្ធភាពគណនេយ្យភាពសភា គឺការអនុវត្តមុខងារស្នូលរបស់សភា ទទួលបានលទ្ធផលល្អប្រសើរ មានតម្លាភាព ចំណាយតិច ទទួលខុសត្រូវខ្ពស់ និងឆ្លើយតបនឹងផលប្រយោជន៍របស់អង្គបោះឆ្នោត និងប្រជាជាតិទាំងមូល។ ប្រសិទ្ធភាពគណនេយ្យភាពសភា មានភាពខុសប្លែកគ្នា អាស្រ័យលើការរៀបចំបោះឆ្នោត (សកល/អសកល) រយៈពេលនីតិកាលសភា (វែង/ខ្លី) និងមណ្ឌលបោះឆ្នោត(តូច/ធំ) ។

### ការបោះឆ្នោតសកល និងអសកល

ការបោះឆ្នោតសកល បង្កើនធម្មានុរូបប្រជាធិបតេយ្យ ផ្តល់អំណាចដល់និងលើកកម្ពស់ការចូលរួមពីពលរដ្ឋ ដែលជាទូទៅត្រូវបានចាត់ទុកថាជាការអនុវត្តតាមគោលការណ៍ប្រជាធិបតេយ្យពេញលេញ។ ការបោះឆ្នោតដោយប្រជាពលរដ្ឋផ្ទាល់បែបនេះ ទោះមានចំណុចល្អច្រើនក៏ជួបបញ្ហានៃការកើនឡើងនូវអ្នកនយោបាយបែបប្រជាភិថុត ច្រើនជាងអ្នកមានសមត្ថភាពពិតប្រាកដ ។ លើសពីនេះទៀត ការរៀបចំការបោះ

ឆ្នោតនឹងត្រូវចំណាយពេលវេលា ធនធានមនុស្ស និងថវិកាច្រើន ដែលមានលក្ខណៈខុសគ្នាពីការបោះឆ្នោតអសកល។

ការបោះឆ្នោតសកលនៅសហរដ្ឋអាម៉េរិក និងអូស្ត្រាលី ធានាថា សមាជិកព្រឹទ្ធសភាមានគណនេយ្យភាពចំពោះអ្នកបោះឆ្នោត បង្កើនភាពស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ និងការជឿទុកចិត្តពីសាធារណជន។ ផ្ទុយទៅវិញ ប្រព័ន្ធបោះឆ្នោតអសកលរបស់បារាំង បានភ្ជាប់ទំនួលខុសត្រូវរបស់សមាជិកព្រឹទ្ធសភាជាមួយមន្ត្រីមូលដ្ឋាន (អង្គបោះឆ្នោត) ប៉ុន្តែធ្វើឱ្យសមាជិកព្រឹទ្ធសភា ឃ្លាតឆ្ងាយពីសាធារណជន។ ការបោះឆ្នោតអសកលកម្ពុជា ធ្វើឱ្យសមាជិកព្រឹទ្ធសភា ទទួលខុសត្រូវជាចម្បងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអង្គបោះឆ្នោត និងអាចមានគម្លាតខ្លះពីប្រជាពលរដ្ឋ។ រីឯ ចក្រភពអង់គ្លេស និងកាណាដា ប្រព័ន្ធតែងតាំងសមាជិកសភាជាន់ខ្ពស់ ធ្វើឱ្យខ្វះគណនេយ្យភាពចំពោះសាធារណជន ដែលបង្កឱ្យមានការទាមទារកំណែទម្រង់ស្ថាប័ននេះជាច្រើនដង។ អំណាចព្រឹទ្ធសភា នៃបណ្តាប្រទេសទាំងនេះក៏ខុសគ្នាដែរ៖ នៅសហរដ្ឋអាម៉េរិក និងអូស្ត្រាលី ព្រឹទ្ធសភាមានសិទ្ធិអំណាចធ្វើច្បាប់ខ្លាំង ខណៈដែលប្រទេសបារាំង ចក្រភពអង់គ្លេស កាណាដា និងកម្ពុជា ផ្តោតលើមុខងារប្រឹក្សាយោបល់ ពិនិត្យសេចក្តីព្រាងច្បាប់ និងតាមដានការអនុវត្តច្បាប់។

## រយៈពេលនៃនីតិកាលសភា

នីតិកាលសភាជាន់ខ្ពស់ដែលមានរយៈពេលវែង ធ្វើឱ្យស្ថាប័នមានស្ថិរភាព និងអនុញ្ញាតឱ្យសមាជិកសភាអភិវឌ្ឍជំនាញ និងផ្តោតលើការធ្វើផែនការគោលនយោបាយរយៈពេលវែង។ ប៉ុន្តែរយៈពេលវែងនេះធ្វើឱ្យសមាជិកសភាជាន់ខ្ពស់ពុំសូវរវងសម្ពាធក្នុងការរក្សានិងស្វែងរក

ការគាំទ្រពីអ្នកបោះឆ្នោត ដែលអាចធ្វើឱ្យមានគម្លាតរវាងពួកគាត់។ ផ្ទុយទៅវិញ នីតិកាលរយៈពេលខ្លី ធ្វើឱ្យសមាជិកសភាជាន់ខ្ពស់ចាំបាច់ទទួលខុសត្រូវ និងឆ្លើយតបទៅតម្រូវការភ្លាមៗរបស់អ្នកបោះឆ្នោត។ យ៉ាងណាក៏ដោយ នីតិកាលខ្លីពេក នឹងធ្វើឱ្យស្ថាប័នសភាជាន់ខ្ពស់ ទោរទន់ទៅរកតែសំឡេងឆ្នោតនិងប្រជាប្រិយភាពនីតិកាលបន្ទាប់ ដោយផ្តោតការធ្វើច្បាប់ឬគោលនយោបាយរយៈពេលខ្លី ជាជាងផលប្រយោជន៍រយៈពេលវែង។

នីតិកាលសភាជាន់ខ្ពស់បារាំង និងអូស្ត្រាលី មានរយៈពេល៦ឆ្នាំ និងបោះឆ្នោតជ្រើសរើសសមាជិកសភាជាន់ខ្ពស់ចំនួនពាក់កណ្តាល (៥0%) រៀងរាល់៣ឆ្នាំម្តងដូចគ្នា ដែលធានាបាននូវនិរន្តរភាព និងស្ថិរភាពក្នុងអភិបាលកិច្ច។ ខណៈដែលសហរដ្ឋអាម៉េរិក បោះឆ្នោតជ្រើសរើសសមាជិកមួយភាគបី(១/៣) រៀងរាល់២ឆ្នាំម្តង ដោយធានាបាននូវសមាជិកព្រឹទ្ធសភាថ្មី ចេញពីការបោះឆ្នោតញឹកញាប់ (Watson & Meyerrose, 2024; Blom, 2024)។ ក៏ប៉ុន្តែការបោះឆ្នោតច្រើនដងក្នុងនីតិកាលមួយ ត្រូវការចំណាយខ្ពស់ និងអាចនាំឱ្យចំនួនប្រជាជនទៅបោះឆ្នោតធ្លាក់ចុះ។ រីឯ នីតិកាលសភាជាន់ខ្ពស់កម្ពុជា មានរយៈពេល៦ឆ្នាំ តាមការបោះឆ្នោតអសកលរៀងរាល់៦ឆ្នាំ ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិករដ្ឋសភា ។ អាណត្តិពេញមួយជីវិតរបស់សមាជិកសភាអភិជនចក្រភពអង់គ្លេស និងការកំណត់អាយុចូលនិវត្តន៍ត្រឹម៧៥ឆ្នាំរបស់សមាជិកព្រឹទ្ធសភាកាណាដា បានផ្តល់នូវស្ថិរភាពសម្រាប់ស្ថាប័ននេះ ប៉ុន្តែបានផ្តាច់សមាជិកចេញពីវដ្តនៃការបោះឆ្នោត ដែលមិនសូវឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន (Transparency International UK, 2024; Hamilton, 2021)។

## វិសាលភាពមណ្ឌលបោះឆ្នោត

ចំពោះមណ្ឌលបោះឆ្នោតដែលមានវិសាលភាពដែនដីធំទូលាយ ជាទូទៅធ្វើឱ្យការជួបប្រាស្រ័យទាក់ទងផ្ទាល់រវាងសមាជិកសភាជាន់ខ្ពស់ជាមួយអ្នកបោះឆ្នោត គឺមិនសូវញឹកញាប់ និងមិនស្និទ្ធស្នាល។ ជាមួយគ្នានេះដែរ ការស្វែងរកដំណោះស្រាយជូនប្រជាជន អំពីកង្វល់និងសំណូមពរ ឱ្យបានទាន់ពេលវេលានិងចំគោលដៅ អាចនៅមានកម្រិត ហើយការចំណាយទាំងធនធានមនុស្ស ពេលវេលា ព្រមទាំងថវិកា គឺច្រើនជាងមណ្ឌលបោះឆ្នោតដែលមានវិសាលភាពដែនដីតូច។ ជាទូទៅ មណ្ឌលបោះឆ្នោតតូច អនុញ្ញាតឱ្យសមាជិកសភាជាន់ខ្ពស់ជួបអ្នកបោះឆ្នោតរបស់ខ្លួនញឹកញាប់ និងមានទំនាក់ទំនងជិតស្និទ្ធ ហេតុដូច្នេះ ការដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា អាចធ្វើឡើងទាន់ពេលវេលាចំគោលដៅ និងចំណាយសមរម្យ ដើម្បីទទួលបានលទ្ធផលល្អគាប់ចិត្ត។

### ៤.សន្និដ្ឋាន

ប្រព័ន្ធបោះឆ្នោត និងការរៀបចំសភាជាន់ខ្ពស់បារាំង ចក្រភពអង់គ្លេស សហរដ្ឋអាម៉េរិក កាណាដា និង  អូស្ត្រាលី បានក្លាយជាធាតុចូលសម្រាប់ការស្វែងរកឧត្តមានុវត្តន៍ដល់ព្រឹទ្ធសភាកម្ពុជា ក្នុងគោលដៅពង្រឹងគណនេយ្យភាពសភា និងប្រសិទ្ធភាពការងារ។ ការស្រាវជ្រាវបង្ហាញ ឱ្យឃើញថា ប្រព័ន្ធបោះឆ្នោតអសកលរបស់បារាំង ធានាឱ្យមានតំណាងក្នុងអភិបាលកិច្ចកម្រិតដែនដីរដ្ឋបាលទី២ រីឯការបោះឆ្នោតសកលរបស់សហរដ្ឋអាម៉េរិក និងអូស្ត្រាលី ផ្តោតលើការបង្កើនគណនេយ្យភាពចំពោះអ្នកបោះឆ្នោត ប៉ុន្តែខ្វះអ្នកតំណាងនៅតាមមូលដ្ឋាន។ ចំពោះ

ប្រព័ន្ធតែងតាំងសមាជិកសភាជាន់ខ្ពស់របស់ចក្រភពអង់គ្លេស និង កាណាដាផ្ដល់អាទិភាពដល់អ្នកជំនាញ អភិជន អ្នកជោគជ័យក្នុងអាជីព បព្វជិតសាសនា និងអ្នកមានមុខមាត់ក្នុងសង្គម ប៉ុន្តែប្រឈមនឹងការ រិះគន់ពីធម្មានុរូបនៃសមាជិក និងប្រជាធិបតេយ្យសភា។ យ៉ាងណាមិញ ប្រព័ន្ធជ្រើសតាំងទាំងអស់ខាងលើនេះ សុទ្ធតែចំណុចល្អ និងបញ្ហា ប្រឈមខុសៗគ្នា។ ដូច្នេះកម្ពុជា អាចទាញយក មេរៀនល្អ និង បទពិសោធពីបណ្ដាប្រទេសទាំងនេះ ជាពិសេសប្រទេសដែលមានការ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក៏ប៉ុន្តែប្រទេសដែលរៀបចំការ បោះឆ្នោតខាងលើ មិនថាសកល ឬអសកល គឺមានមណ្ឌលបោះឆ្នោត នៅដែនដីកម្រិត១ ឬកម្រិត២ ខុសប្លែកពីការអនុវត្តនៃព្រឹទ្ធសភាកម្ពុជា ដែលមណ្ឌលបោះឆ្នោតស្ថិតនៅកម្រិតភូមិភាគ គឺភាគច្រើនយកដែន ដីកម្រិត១ បូកបញ្ចូលគ្នា ផ្ទុយពីការអនុវត្តជាទូទៅក្នុងពិភពលោក។ យោងលើលទ្ធផលនៃការស្រាវជ្រាវនេះ កម្ពុជា គួរសិក្សាកែសម្រួលប្រព័ន្ធ បោះឆ្នោត ដើម្បីពង្រឹងភាពតំណាង ប្រសិទ្ធភាពប្រជាធិបតេយ្យ និង គណនេយ្យភាពរបស់ព្រឹទ្ធសភា ដោយផ្លាស់ប្ដូរមណ្ឌលបោះឆ្នោត ពី កម្រិតភូមិភាគ ទៅដែនដីរដ្ឋបាលកម្រិត១ និងកំណត់ចំនួនអាសនៈ សមាជិកព្រឹទ្ធសភាក្នុងមណ្ឌលបោះឆ្នោតនីមួយៗ ផ្អែកទៅតាមទំហំ មណ្ឌលបោះឆ្នោត។

## ៥. អនុសាសន៍

- ពិចារណាផ្លាស់ប្ដូរមណ្ឌលបោះឆ្នោត៖ ព្រឹទ្ធសភាកម្ពុជា គួរប្ដូរ មណ្ឌលបោះឆ្នោតពីភូមភាគទាំង ៨ ទៅកម្រិតរាជធានី-ខេត្ត ទាំង២៥ វិញ ដូចកាអនុវត្តនៅរដ្ឋសភា ដើម្បីបង្កើនគណនេយ្យ

ភាពចំពោះអង្គបោះឆ្នោត ជានាទំនាក់ទំនងកាន់តែជិតស្និទ្ធ រវាងសមាជិកព្រឹទ្ធសភា និងសហគមន៍មូលដ្ឋាន។

- ពិចារណាប្រើប្រាស់ប្រព័ន្ធបោះឆ្នោតកូនកាត់ (Hybrid)៖ ទទួលយកប្រព័ន្ធចម្រុះ ដោយមានការបោះឆ្នោតសកល សម្រាប់សមាជិកព្រឹទ្ធសភាមួយចំនួន និងរក្សាការបោះឆ្នោតអសកលសម្រាប់សមាជិកព្រឹទ្ធសភាមួយចំនួនផ្សេងទៀត។
- ពិចារណាបង្កើតការបោះឆ្នោតពាក់កណ្ដាលអាណត្តិ៖ អនុវត្តអាណត្តិរយៈពេល៦ឆ្នាំ ជាមួយនឹងការបោះឆ្នោតពាក់កណ្ដាលអាណត្តិរៀងរាល់៣ឆ្នាំម្ដង ដើម្បីធានាបាននូវនិរន្តរភាព និងការត្រួតពិនិត្យជាប្រចាំ។

# ឯកសារយោង


1. Research Starters. (2025). *Parliamentary system*. EBSCO. Retrieved from [Parliamentary system | Research Starters - EBSCO]
2. Britannica, T. Editors of. (2024). *Parliamentary system | Definition & facts*. Encyclopædia Britannica. Retrieved from [Parliamentary system | Definition & Facts - Britannica]
3. Wikipedia contributors. (2023). *Bicameralism*. Wikipedia, The Free Encyclopedia. Retrieved from Bicameralism - Wikipedia
4. Investopedia. (2024). *Bicameral system: What it is, how it works, history in U.S.* Retrieved from Bicameral System: What It Is, How It Works, History in U.S. - Investopedia
5. Britannica, T. Editors of. (n.d.). *Bicameral system | Definition, legislature, & example*. Encyclopædia Britannica. Retrieved from Bicameral system | Definition, Legislature, & Example - Britannica
6. OneMoneyWay. (2024). *A guide to understanding the bicameral legislature system*. Retrieved from A guide to understanding the bicameral legislature system - OneMoneyWay
7. Brainly.in. (n.d.). *What are the advantages of bicameral legislature?* Retrieved from what are the advantages of bicameral legislature? - Brainly.in
8. International IDEA. (2014). *Bicameralism*. Retrieved from Bicameralism - International IDEA
9. List of administrative divisions by country. (2023) https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country
10. Fontanelli O, Miramontes P, Cocho G, Li W. (2017). Population patterns in World's administrative units. R. Soc. open sci. 4: 170281. http://dx.doi.org/10.1098/rsos.170281

https://pmc.ncbi.nlm.nih.gov/articles/PMC5541548/pdf/rsos170281.pdf

## បារាំង

1. European Parliament. (2023). *The French Senate*. Retrieved from [THE FRENCH SENATE - European Parliament]
2. Smith, J. (2021). *The French National Assembly and Senate: A subservient parliament*. Retrieved from [The French National Assembly and Senate – A subservient parliament]
3. IPEX.eu. (2023). *French Sénat*. Retrieved from [French Senat - IPEX.eu]
4. Wikipedia contributors. (2023). *Senate (France)*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/Senate_(France)
5. Sénat. (2024). *The senatorial elections | The French Senate*. Retrieved from [The senatorial elections | The French Senate - Sénat]
6. Wikipedia contributors. (2023). *French Senate elections*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/French_Senate_elections
7. Sénat. (n.d.). *The French Senate*. Retrieved from [The French Senate - Sénat]

## អាម៉េរិក

1. Swearingen, C., & Ripberger, J. T. (2011). Examining the effect of public attention on U.S. Senate election outcomes. *SSRN Electronic Journal*. https://doi.org/10.2139/ssrn.1924574
2. Druckman, J. N. (2004). Priming the vote: Campaign effects in a U.S. Senate election. *Political Psychology*, 25 (4), 577–594. https://doi.org/10.1111/j.1467-9221.2004.00388.x (Wiley Online Library)

3. Wikipedia contributors. (2023). *History of the United States Senate*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/History_of_the_United_States_Senate
4. Wikipedia contributors. (2023). *United States Senate*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/United_States_Senate
5. U.S. Capitol Visitor Center. (2024). *The U.S. Senate*. Retrieved from [The U.S. Senate - U.S. Capitol - Visitor Center]
6. Ben's Guide. (n.d.). *Election of Senators*. Retrieved from [Election of Senators - Ben's Guide]
7. U.S. Senate. (2025). *About electing and appointing senators*. Retrieved from [About Electing and Appointing Senators - U.S. Senate]
8. Britannica. (n.d.). *United States Senate: Definition, history, & facts*. Retrieved from [United States Senate | Definition, History, & Facts - Britannica]
9. U.S. Senate. (n.d.). *Powers and procedures*. Retrieved from [Powers and Procedures - U.S. Senate]
10. Arizona Clean Elections Commission. (2024). *U.S. Senators*. Retrieved from [U.S. Senators - Arizona Clean Elections Commission]
11. U.S. Senate. (2024). *Origins and foundations*. Retrieved from [Origins and Foundations - U.S. Senate]
12. Bloomberg Government. (n.d.). *Balance of power in the U.S. House and Senate*. Retrieved from [Balance of Power in the U.S. House and Senate - Bloomberg Government]
13. Wikipedia contributors. (2023). *List of current United States senators*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/List_of_current_United_States_senators

14. The Independent. (n.d.). *Senate - latest news, breaking stories and comment*. Retrieved from [Senate - latest news, breaking stories and comment - The Independent]
15. Wikipedia contributors. (2023). *United States Senate*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/United_States_Senate
16. U.S. Legal System. (n.d.). *Senate*. Retrieved from [US Senate | The Guardian]
17. Congress.gov. (n.d.). *The legislative process: Executive business in the Senate (Video)*. Retrieved from [The Legislative Process: Executive Business in the Senate (Video) | Congress.gov]
18. Citizens Clean Elections Commission. (n.d.). *U.S. Senators*. Retrieved from [U.S. Senators - Citizens Clean Elections Commission]
19. *Navigating the balance of power in the US House and Senate to drive policy wins*. Retrieved from [Navigating the Balance of Power in the US House and Senate to Drive Policy Wins]
20. Cook Political Report. (2026). *2026 CPR Senate race ratings*. Retrieved from [2026 CPR Senate Race ratings - Cook Political Report]
21. Boston Review. (n.d.). *Democracy v. the Constitution*. Retrieved from [Democracy v. the Constitution - Boston Review]
22. U.S. Government Accountability Office. (n.d.). *Now that the election is over, here are some of the major issues facing the nation and next Congress*. Retrieved from [Now that the Election is Over, Here are Some of the Major Issues Facing the Nation and Next Congress | U.S. GAO]

# ចក្រកពអង់គ្លេស


1. Wikipedia contributors. (2023). *House of Lords*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/House_of_Lords

2. UK Parliament. (2025). *What does the House of Lords do?*

3. Britannica. (n.d.). *House of Lords | British Parliament, History & Powers*. Retrieved from [link]

4. Wikipedia contributors. (2023). *List of current members of the House of Lords*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/List_of_current_members_of_the_House_of_Lords

5. UK Parliament. (2024). *House of Lords reform*. Retrieved from [link]

6. Russell, M. (2023). *House of Lords reform: Navigating the obstacles*. Institute for Government. Retrieved from https://www.instituteforgovernment.org.uk/sites/default/files/2023-03/House-of-Lords-reform-guest-paper.pdf

7. Transparency International UK. (2024). *Reducing corruption risks in a reformed House of Lords*. Retrieved from https://www.transparency.org.uk/sites/default/files/2024-12/Reducing%20Corruption%20Risks%20In%20A%20Reformed%20House%20Of%20Lords%20-%20Transparency%20International%20UK_0.pdf

8. UK Parliament (n.d.), *How members are appointed*. Retrieved from https://www.parliament.uk/business/lords/whos-in-the-house-of-lords/members-and-their-roles/how-members-are-appointed/#:~:text=The%20Appointments%20Commission

%20recommends%20individuals,(after%20a%20general%20election).

## កាណាដា


1. Gidda, N. (2018). *Parliamentary reform in Canada: The significance of Senate reform*. *Political Science Undergraduate Review, 3* (1), 1–10. https://journals.library.ualberta.ca/psur/index.php/psur/article/download/15/13
2. Hamilton, B. (2021). *Canada's Senate: The need for reform*. *Gadfly, 1* (1), 1–10. https://journals.lib.sfu.ca/index.php/gadfly/article/download/2927/3025
3. Parliament of Canada. (n.d.). *The role of the Senate*. Retrieved from [The Role of the Senate - Learn About Parliament]
4. The Canadian Encyclopedia. (2022). *Senate of Canada*. Retrieved from [Senate of Canada - The Canadian Encyclopedia]
5. Barriston Law. (n.d.). *The Canadian Senate*. Retrieved from [The Canadian Senate - Barriston Law]
6. Government of Canada. (2024). *About the Senate*. Retrieved from [About the Senate - Canada.ca]
7. Senate GRO. (2023). *The road to renewal*. Retrieved from [The Road to Renewal - Senate GRO]
8. Wikipedia contributors. (2023). *Senate of Canada*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/Senate_of_Canada
9. Cram. (n.d.). *Essay on Canadian Senate*. Retrieved from [Senate of Canada - Wikipedia]
10. Bartleby.com. (n.d.). *Essay on Canadian Senate*. Retrieved from [Essay On Canadian Senate - 617 Words | Cram]

11. StudyMode. (n.d.). *Advantages and disadvantages of Senate in Canada*. Retrieved from [Advantages And Disadvantages Of Senate In Canada - StudyMode]
12. IPL.org. (n.d.). *Essay on Canadian Senate reform*. Retrieved from [Essay On Canadian Senate Reform - 1425 Words - IPL.org]
13. University of Toronto Press. (n.d.). *The Senate of Canada*. Retrieved from [THE SENATE OF CANADA - University of Toronto Press]

## អូស្ត្រាលី

1. Blom, M. (2024). *Analysing guarantees in Australian Senate outcomes*. arXiv preprint arXiv:2403.13275. https://arxiv.org/pdf/2403.13275
2. The Australia Institute. (2021). *Representative, still: The role of the Senate in our democracy*. https://australiainstitute.org.au/wp-content/uploads/2021/03/Representative-Still-the-role-of-the-Senate-in-our-democracy.pdf
3. Parliament of Australia. (2025). *About the Senate*. Retrieved from [link]
4. Wikipedia contributors. (2023). *Australian Senate*. In *Wikipedia, The Free Encyclopedia*. Retrieved from https://en.wikipedia.org/wiki/Australian_Senate




*CONTACT*

**ASEAN Economic Research Institute (AERI)**
National University of Management,
International Campus, Khan Chbar
Ampov, Phnom Penh
www.aeri.num.edu.kh
aeri@num.edu.kh